# គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖

## ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ
## ស្តីពី
## “ការការពារ ការគោរព និងដំណោះស្រាយ”

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា

# គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖

# ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ
# ស្តីពី
# “ការការពារ ការគោរព និងដំណោះស្រាយ”


អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា


ខែ ធ្នូ ឆ្នាំ២០១១

*សំរាប់ពត៌មានបន្ថែមសូមធ្វើការទំនាក់ទំនងមក*

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ផ្ទះលេខ១០ ផ្លូវ៣០២សង្កាត់បឹងកេងកង១
ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ +៨៥៥២៣៩៩៣៥៩០/ ៩៨៧៦៧១

# មាតិកា

បុព្វកថា ............ ៥

សំណួរដែលត្រូវបានសួរជាញឹកញាប់
I – សេចក្តីផ្តើមស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស ............ ៧
II – គោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស ............ ១០
III – ការអនុវត្តន៍បទដ្ឋានផ្សេងៗនៅក្នុងប្រទេសកម្ពុជា ............ ១២
IV – តើហេតុអ្វីបានជាគោលការណ៍ណែនាំនេះ
មានសារៈប្រយោជន៍? ............ ១៣
V – ព័ត៌មានបន្ថែម ............ ២២

ឧបសម្ព័ន្ធ៖ ច្បាប់ និងបទប្បញ្ញត្តិមួយចំនួនរបស់កម្ពុជា
ដែលអនុវត្តបានចំពោះ ធុរកិច្ច និងសិទ្ធិមនុស្ស ............ ២៤

គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖
ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពី
"ការការពារ ការគោរព និង ដំណោះស្រាយ"

គោលការណ៍ទូទៅ ............ ២៧

I. រដ្ឋមានភារកិច្ចការពារសិទ្ធិមនុស្ស ............ ២៩
ក. គោលការណ៍ជាមូលដ្ឋាន ............ ២៩
ខ. គោលការណ៍ប្រតិបត្តិការ ............ ២៩

II. ទំនួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស ............ ៣៣
ក. គោលការណ៍ជាមូលដ្ឋាន ............ ៣៣
ខ. គោលការណ៍ប្រតិបត្តិការ ............ ៣៥

III. ការទទួលបានការដោះស្រាយ ............ ៤១
ក.គោលការណ៍ជាមូលដ្ឋាន ............ ៤១
ខ.គោលការណ៍ប្រតិបត្តិការ ............ ៤១

## បុព្វកថា

សហគ្រាសពាណិជ្ជកម្ម គឺជាមធ្យោបាយជាសកលដ៏សំខាន់សំរាប់ការទទួលបានសិទ្ធិមនុស្ស។ ជាឧទាហរណ៍ វាអាចរួមចំណែកតាមរយៈការបង្កើតការងារនិងមុខរបរ ការអភិវឌ្ឍន៍ និងទំនើបភាវូបនីយកម្មនៅមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីសកម្មភាពធុរកិច្ច នៅតែបន្តជាបញ្ហាប្រឈមដ៏សំខាន់មួយជាដដែល។ បទដ្ឋានថ្មីមួយនេះបានបំភ្លឺពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋនិងសហគ្រាសពាណិជ្ជកម្ម ដែលបទដ្ឋានទាំងនេះបានរួមបញ្ចូលគ្នានិងដោយបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នូវគោលការណណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្សនៅក្នុងខែ មិថុនា ឆ្នាំ ២០១១។

នៅកម្ពុជា ការធ្វើវិនិយោគទុនដោយក្រុមហ៊ុនសារជីវកម្មជាតិ និងអន្តរជាតិគឺជាកម្លាំងចលករដ៏សំខាន់មួយនៃការអភិវឌ្ឍន៍ជាតិ និងមិនត្រូវមានផលប៉ះពាល់អវិជ្ជមានទៅលើសហគមន៍មូលដ្ឋានឡើយ។ គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ផ្តល់ផែនទីបង្ហាញផ្លូវមួយសំរាប់រដ្ឋ និងក្រុមហ៊ុនសាជីវកម្មផ្សេងៗ ក៏ដូចជា សង្គមស៊ីវិល បុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគ្រប់គ្រងរលកថ្មីនៃការអភិវឌ្ឍន៍អោយបានល្អប្រសើរឡើងថែមទៀត ទន្ទឹមនេះ វាក៏ជួយបន្ថែមតំលៃរបស់សហគ្រាសពាណិជ្ជកម្មផងដែរ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (ការិយាល័យ OHCHR) ដែលជាការិយាល័យធំបំផុតមួយ

ដែលមានវត្តមាននៅតាមប្រទេសរបស់ OHCHR ប្តេជ្ញាចិត្តដើម្បីធ្វើការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជាមួយអ្នកពាក់ព័ន្ធទាំងឡាយតាមរយៈការឃ្លាំមើល ការការពារ សហប្រតិបត្តិការបច្ចេកទេស ការកសាងសមត្ថភាពតួអង្គដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន និងពង្រឹងគណនេយ្យភាពរដ្ឋ និងសហគ្រាសពាណិជ្ជកម្ម។ សៀវភៅនេះ មានគោលបំណងផ្តល់ការណែនាំដល់ដៃគូនានា ក្នុងការអនុវត្តន៍គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សនៅកម្ពុជា ។

ការិយាល័យOHCHR ប្រចាំកម្ពុជា
ខែធ្នូ ឆ្នាំ២០១១

## I. សេចក្តីផ្តើមស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស

ការយល់ដឹងរបស់សង្គម អំពីការអនុវត្តន៍របស់សហគ្រាសពាណិជ្ជកម្ម បានចាប់ផ្តើមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ និងបានកើនឡើងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ជាមួយនឹងការរីកលូតលាស់ជាអន្តរជាតិនៃវិស័យឯកជន។ មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើង អំពីផលប៉ះពាល់របស់ធុរកិច្ចទៅលើសិទ្ធិមនុស្ស។ ប្រជាពលរដ្ឋបានចាប់ផ្តើមសួរសំណួរថាតើ ធុរកិច្ចទាំងឡាយត្រូវបានគេចាប់ឲ្យទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនឬទេ។ នេះរាប់ទាំងធុរកិច្ចទាំងឡាយ ដែលមានរដ្ឋ ធ្វើជាម្ចាស់ គ្រប់គ្រង ឬដាក់ឲ្យប្រតិបត្តិការទាំងស្រុង ឬមួយផ្នែក។

**សិទ្ធិមនុស្ស** គឺជាសិទ្ធិជាមូលដ្ឋានដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបាន។ សិទ្ធិមនុស្ស គឺជាបទដ្ឋានអន្តរជាតិ សំរាប់បុគ្គលគ្រប់រូបដែលត្រូវទទួលបាននូវការប្រព្រឹត្តមកលើខ្លួនដោយសមភាព និងសេចក្តីថ្លៃថ្នូរ

មូលដ្ឋានគ្រឹះ សំរាប់ភារកិច្ចរបស់រដ្ឋ ក្នុងការការពារប្រឆាំងនឹងការរំលោភបំពានពីភាគីទីបី រួមមានទាំងសហគ្រាសពាណិជ្ជកម្មផង ស្ថិតលើតម្លៃស្នូលនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងអស់។ ទន្ទឹមគ្នានេះដែរ ស្ទើរតែគ្រប់សិទ្ធិមនុស្សទាំងអស់ អាចត្រូវរងការប៉ះពាល់ពីសកម្មភាពរបស់ធុរកិច្ច ទាំងដោយផ្ទាល់ក្តី ឬប្រយោលក្តី។ ដោយសារតែផល

ប៉ះពាល់អាចធ្ងន់ធ្ងរជាសក្តានុពល ដូច្នេះគ្រប់ធុរកិច្ចទាំងអស់នៅក្នុងគ្រប់វិស័យឧស្សាហកម្មទាំងអស់ មានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស។ ទោះបីជា ភារកិច្ចការពារ និងបំពេញសិទ្ធិមនុស្ស នៅតែជាបន្ទុករបស់រដ្ឋាភិបាលប្រទេសនានាក្តី ក៏មានការកើនឡើងនូវចំនួនធុរកិច្ច ដែលទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួន ហើយដែលកំពុងតែចាត់វិធានការវិជ្ជមាន ដើម្បីលើកស្ទួយសិទ្ធិមនុស្ស តាមរយៈការងាររបស់ខ្លួន។

**សហគ្រាសពាណិជ្ជកម្ម** សំដៅទៅលើ ធុរកិច្ចទាំងអស់ទាំងជាទំរង់ឆ្លងដែន និងទំរង់ដទៃទៀត ដោយមិនគិតពីវិស័យ ឬប្រទេសដែលសហគ្រាសពាណិជ្ជកម្មនោះតាំងនៅ ឬធ្វើប្រត្តិបត្តការ និងដោយមិនគិតពី ទំហំ ទំរង់ ឬរចនាសម្ព័ន្ធសហគ្រាសពាណិជ្ជកម្មឡើយ

## *តើធុរកិច្ច និងសិទ្ធិមនុស្ស ខុសប្លែកគ្នាពីការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម យ៉ាងដូម្តេច?*

នៅក្នុងអតីតកាល សហគ្រាសពាណិជ្ជកម្មនានា មាននិន្នាការដោះស្រាយបញ្ហាសង្គម តាមរយៈកម្មវិធីទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម(CSR) របស់ខ្លួន។ ការទទួលខុសត្រូវរបស់សាជីវកម្ម ចំពោះសង្គមជារឿយៗត្រូវបានគេមើលឃើញថា ជាវិធីមួយដែលឧស្សាហកម្មបញ្ចូលកង្វល់អំពីសេដ្ឋកិច្ច សង្គម និងបរិស្ថាន ទៅក្នុងសកម្មភាពការងាររបស់ខ្លួន។ ទោះជាដូច្នេះក្តី គំនិតផ្តួចផ្តើមជាច្រើនរបស់ ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម បានធ្វើឡើងតាមការជ្រើសរើស មានលក្ខណៈអាដហុក និងមានត្រឹមតែសកម្មភាពមនុស្សធម៌។ វាផ្អែកលើអ្វី ដែលក្រុមហ៊ុន

ជ្រើសរើសយកមកដោះស្រាយតាមការចង់បានរបស់ខ្លួន។

ផ្ទុយទៅវិញ ការគោរពសិទ្ធិមនុស្ស មិនមែនជាការធ្វើឡើងតាមការស្ម័គ្រចិត្តនោះទេ។ ការគោរពសិទ្ធិមនុស្ស តម្រូវនូវការប្តេជ្ញាចិត្តពីធុរកិច្ច។ ក្របខ័ណ្ឌសិទ្ធិមនុស្ស ផ្តល់នូវការទទួលស្គាល់ជាសាកល ការគិតគូរជាចម្បងដល់ប្រជាពលរដ្ឋចំពោះផលប៉ះពាល់សង្គម និងបរិស្ថានរបស់ធុរកិច្ច។ ដើម្បីសម្រេចបានការទទួលខុសត្រូវរបស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្សមានការរំពឹងទុកថា សហគ្រាសពាណិជ្ជកម្ម អនុវត្តគោលនយោបាយដើម្បីទប់ស្កាត់ និងដោះស្រាយចំពោះផលអវិជ្ជមានជាសក្តានុពល និងជាក់ស្តែងកើតចេញមកពីសកម្មភាពរបស់ខ្លួន។

### *តើអង្គការសហប្រជាជាតិបានដោះស្រាយយ៉ាងដូម្តេច ចំពោះធុរកិច្ច និងសិទ្ធិមនុស្ស?*

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្តួចផ្តើមអោយមាននូវ 'គ្លូបលកំផែក' ដោយស្ម័គ្រចិត្តមួយនៅក្នុងឆ្នាំ ២០០០ ជាវេទិកាពិភពលោក ដែលប្រមូលផ្តុំនូវការជួបប្រជុំគ្នារបស់ធុរកិច្ចទាំងឡាយ និងទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ផ្នែកកម្មករ និងសង្គមស៊ីវិលដើម្បីគាំទ្រដល់សិទ្ធិមនុស្ស ពលកម្ម បរិស្ថាន និងប្រឆាំងអំពើពុករលួយ។ ក្នុងឆ្នាំ២០០៥ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (ក្នុងឆ្នាំ២០០៦ ជំនួសដោយ ក្រុមប្រឹក្សាសិទ្ធិមនុស្ស) បានតែងតាំងសាស្ត្រាចារ្យ ចន រ៉ាក់គី ជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើបញ្ហាសិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងទៀត។ អាណត្តិការងារត្រូវបានប្រគល់ដល់រូប

គាត់ ដើម្បីធ្វើការកំណត់ និងស្រាយបំភ្លឺបទដ្ឋាននានាអំពី ការទទួលខុសត្រូវ និងគណនេយ្យភាពសាជីវកម្មចំពោះសិទ្ធិមនុស្ស រាប់បញ្ចូលទាំងតួនាទីរបស់រដ្ឋផងដែរ។ អ្នកតំណាងពិសេសបានស្នើឡើងនូវក្របខ័ណ្ឌគោលនយោបាយស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ" ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់ អង្គការសហប្រជាជាតិបានស្វាគមន៍ជាឯកច្ឆ័ន្ទ ក្នុងឆ្នាំ២០០៨។ ក្របខ័ណ្ឌនេះរួមមានសរសរទ្រូងបី គឺ៖

**រដ្ឋមានតួនាទីការពារ**ប្រឆាំង នឹងការរំលោភសិទ្ធិមនុស្សដោយភាគីទីបី រាប់បញ្ចូលទាំងសហគ្រាសពាណិជ្ជកម្ម តាមរយៈគោលនយោបាយ បទបញ្ញា និងសេចក្តីសំរេច ។

**ការទទួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរព**សិទ្ធិមនុស្ស ដែលមានន័យថា សហគ្រាសពាណិជ្ជកម្មទាំងឡាយ គួរតែធ្វើសកម្មភាពដោយយកចិត្តទុកដាក់បំផុត ជៀសវាងការរំលោភបំពានលើសិទ្ធិអ្នកដទៃ និងដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន។

សេចក្តីត្រូវការឲ្យ**ទទួលបានការដោះស្រាយ** កាន់តែទូលំទូលាយឡើងសំរាប់ជនរងគ្រោះនៃអំពើរំលោភបំពានទាក់ទងនឹងធុរកិច្ច ទាំងតាមប្រព័ន្ធយុត្តិធម៌ និងក្រៅប្រព័ន្ធយុត្តិធម៌។

## II. គោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស

### *តើគោលការណ៍ណែនាំគឺជាអ្វី?*

គោលការណ៍ណែនាំ គឺជាសំណុំនៃគោលការណ៍ចំនួន ៣១ ដែលគាំទ្រដល់ការអនុវត្តន៍ក្របខ័ណ្ឌគោលនយោបាយ របស់អង្គការសហប្រជាជាតិ ស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ"។ គោលការណ៍

ណែនាំនេះមានមូលដ្ឋានលើសសរសរទ្រូងបីគឺ "ការការពារ ការគោរព និង ដំណោះស្រាយ"។ គោលការណ៍ណែនាំនេះជាផលិតផល ដែលកើតចេញពីការសិក្សាស្រាវជ្រាវ និង ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ រយៈពេលប្រាំមួយឆ្នាំ ដែលមានការចូលរួមពីសំណាក់រដ្ឋាភិបាល សមាគម និង សហគ្រាសពាណិជ្ជកម្ម សង្គមស៊ីវិល បុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ និងវិនិយោគិន។ ពួកគេ*គូសបញ្ជាក់ អំពីវិធានការទាំងឡាយដែលរដ្ឋនានាគួរតែចាត់ឡើង* ដើម្បីជំរុញឲ្យធុរកិច្ចទាំងឡាយ គោរពសិទ្ធិមនុស្ស *ផ្តល់គម្រោងដល់ធុរកិច្ចទាំងឡាយអោយបាន*ដឹង និងអោយបង្ហាញអោយគេឃើញថា ពួកគេគោរពសិទ្ធិមនុស្ស និងកាត់បន្ថយហានិភ័យ នៃការបង្កឲ្យមាន ឬការរួមចំណែកធ្វើឲ្យអន្តរាយដល់សិទ្ធិមនុស្ស និង បង្កើតនូវ*ខ្នាតរង្វាស់សំរាប់អ្នកដែលពាក់ព័ន្ធ* ដើម្បីវាយតំលៃអំពីការគោរពសិទ្ធិមនុស្សរបស់ធុរកិច្ច។ គោលការណ៍ទាំងនេះក៏មានចែងអំពីអ្វី ដែលទាំងរដ្ឋ និង សហគ្រាសពាណិជ្ជកម្មគួរតែធ្វើ ដើម្បីធ្វើអោយប្រសើរឡើងដល់ការទទួលបាននូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព សំរាប់បុគ្គលទាំងឡាយណា ដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន។

### *តើអ្វីទៅជា "ឋានៈ" របស់គោលការណ៍ណែនាំ?*

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆ័ន្ទលើគោលការណ៍ណែនាំ (សេចក្តីសំរេចចិត្តលេខ ១៧/៤)។ ខណៈដែលឯកសារនេះមិនចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ ប៉ុន្តែការអនុម័តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានបង្កើតអោយគោលការណ៍ណែនាំនេះ ក្លាយទៅជាចំណុចយោងជាសកលសំរាប់អនុវត្តបានចំពោះ ធុរកិច្ច និងសិទ្ធិមនុស្ស។

នៅពេលអនុម័តគោលការណ៍ណែនាំនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្ស (A/HRC/១៧/៤ កថាខ័ណ្ឌ ៦) ក៏បានបង្កើតផងដែរនូវក្រុមការងារស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស (មានសមាសភាពអ្នកជំនាញការឯករាជ្យ ចំនួនប្រាំរូប) ដើម្បីលើកស្ទួយការអនុវត្តន៍គោលការណ៍ណែនាំនេះ ព្រមទាំងបង្កើតអោយមានឡើងនូវវេទិកាប្រចាំឆ្នាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស ដោយស្ថិតក្រោមការណែនាំរបស់ក្រុមការងារ។

## III. ការអនុវត្តន៍បទដ្ឋានផ្សេងៗនៅក្នុងប្រទេសកម្ពុជា

### *តើធុរកិច្ច និង បទដ្ឋានសិទ្ធិមនុស្សទាក់ទងគ្នាយ៉ាងដូចម្តេចទៅនឹងបរិបទប្រទេសកម្ពុជា?*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ តំកល់កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ៖ "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ"។ ដោយសារគោលការណ៍ណែនាំនេះឈរលើគ្រឹះនៃការទទួលស្គាល់កាតព្វកិច្ចស្រាប់របស់រដ្ឋនានាក្នុងការគោរព ការការពារ និងការបំពេញសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ដូច្នេះ បទដ្ឋានស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស មានតម្លៃអនុវត្តបានដោយផ្ទាល់ ដោយព្រះរាជាណាចក្រកម្ពុជា តាមរយៈការប្តេជ្ញាចិត្តគោរពតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិរបស់ខ្លួន។

វិស័យអាជីវកម្ម សំខាន់ៗមួយចំនួនទាក់ទងនឹងបរិបទកម្ពុជា ប៉ុន្តែមិនកម្រិតតែត្រឹមនេះ រួមមាន៖ កសិអាជីវកម្ម (មានជាអាទិ៍ ចំការអំពៅ

ចំការកៅស៊ូ ចំការដំឡូងមី និងចំការអាកាស្យា) ផលិតកម្មឧស្សាហកម្មទាំង នៅតំបន់ទីប្រជុំជន និងនៅតំបន់ជនបទ (ជាពិសេសទាក់ទងនឹងរោងចក្រ និង សម្បទានដីសេដ្ឋកិច្ច) ឧស្សាហកម្មទាញយករ៉ែ (មានជាអាទិ៍ ការទាញយករ៉ែ ប្រេង និងឧស្ម័ន) ទេសចរណ៍ និងបដិសណ្ឋារកិច្ច (មានដូចជា សណ្ឋាគារ និងភោជនីយដ្ឋាន) ហេដ្ឋារចនាសម្ព័ន្ធ និងគំរោងអភិវឌ្ឍន៍នានា (មានដូចជា ការស្ថាបនាផ្លូវជាតិ និងផ្លូវដែក) សេវាការងារ និងមុខរបរ (រាប់ទាំង ទីភ្នាក់ជ្រើសរើសកម្មករបំរើការងារក្នុងស្រុក) គំរោងថាមពល (ដូចជា ទំនប់វ៉ារីអគ្គីសនី និងរោងចក្រផលិតឡូងថ្ម) និងសហគ្រាសខ្នាតមធ្យម និងខ្នាតតូចដទៃទៀត រាប់ទាំងអាជីវកម្មជាលក្ខណៈគ្រួសារ។

## IV. តើហេតុអ្វីបានជាគោលការណ៍ណែនាំនេះមានសារៈប្រយោជន៍?

### *សំរាប់រដ្ឋាភិបាល៖*

<u>ការធានាការពារបង្ការការរំលោភបំពាន</u>៖ គោលការណ៍ណែនាំនេះផ្តល់ការណែនាំ និងអនុសាសន៍ សំរាប់វិធានការរបស់រដ្ឋាភិបាល តាមរយៈ គោលនយោបាយ ច្បាប់ បទបញ្ជា និងសេចក្តីសំរេចនានាដើម្បីទប់ស្កាត់ កាត់បន្ថយ និងដោះស្រាយ ចំពោះការរំលោភបំពានសិទ្ធិមនុស្ស។ កាតព្វកិច្ច ក្រោមសន្ធិសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាលទាំងឡាយ ក្នុងការការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សដោយភាគីទីបី ស្ថិតនៅក្នុងរង្វង់ដែនដី និង/ឬ ដែនសមត្ថកិច្ចរបស់ខ្លួន (ក្នុងនោះមាន គោលការណ៍លេខ១ និង លេខ២)។ គោលការណ៍ណែនាំក៏បានផ្តល់ការណែនាំផងដែរដល់ធុរកិច្ចនានាដែលមានរដ្ឋធ្វើជាម្ចាស់ ឬគ្រប់គ្រងដោយរដ្ឋ។

គោលនយោបាយស៊ីសង្វាក់គ្នា៖ មានហេតុផលខាងគោលនយោបាយសំរាប់រដ្ឋសាម៉ី ដើម្បីកំណត់អោយបានច្បាស់លាស់ អំពីការរំពឹងទុកថា ធុរកិច្ចទាំងឡាយគោរពសិទ្ធិមនុស្សនៅក្នុងរដ្ឋរបស់ខ្លួន និងនៅបរទេស។ គោលការណ៍ណែនាំ ផ្តល់ការណែនាំដល់រដ្ឋាភិបាលអោយធានាបាននូវ គោលនយោបាយស៊ីសង្វាក់គ្នានេះ (លេខ៨ ដល់ លេខ១០) សំរាប់ស្ថាប័ននានារបស់ខ្លួន និងភាគីទីបី។ គោលការណ៍ណែនាំ ផ្តល់ការណែនាំអំពី ការពិនិត្យដោយត្រឹមត្រូវលើសិទ្ធិមនុស្ស (លេខ១៧ ដល់ លេខ២១) រួមទាំងការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់សំរាប់អោយរដ្ឋនានា យកទៅប្រើប្រាស់ នៅពេលចូលពាក់ព័ន្ធជាមួយធុរកិច្ច ឬគ្រប់គ្រងមើលលើគំរោងផ្សេងៗ។

ការកាត់បន្ថយហានិភ័យ៖ រដ្ឋាភិបាលទាំងឡាយមិនគួរសន្មត់ថាខ្លួនកំពុងជួយដល់ធុរកិច្ច តាមរយៈការមិនដាក់ឲ្យពួកគេទទួលខុសត្រូវនោះឡើយ ផ្ទុយទៅវិញ ធុរកិច្ចទាំងឡាយដែលមិនមានការធានាការពារផ្នែកច្បាប់ និងនីតិវិធីសមស្របទៅវិញទេ ដែលត្រូវប្រឈមនឹងហានិភ័យខ្ពស់ ដែលអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ខ្លួន ស្ថានភាពគតិយុត្ត និងផលកម្រៃ (លេខ៣)។ បន្ថែមពីលើនេះទៀត ធុរកិច្ចជាច្រើនក៏បានងាកទៅរករដ្ឋាភិបាល ដើម្បីទទួលបាននូវ យោបល់ ការណែនាំ និងសេចក្តីរំពឹងទុកច្បាស់លាស់ សំរាប់ការប្រព្រឹត្តទៅនៃធុរកិច្ចរបស់ខ្លួន។ ចំពោះធុរកិច្ចដែលរដ្ឋធ្វើជាម្ចាស់ ឬគ្រប់គ្រងដោយរដ្ឋ (លេខ៤) គោលការណ៍ណែនាំនេះផ្តល់មធ្យោបាយ ដើម្បីគ្រប់គ្រងអោយបានកាន់តែប្រសើរឡើងលើកេរ្តិ៍ឈ្មោះ និងហានិភ័យផ្លូវច្បាប់ ដែលនឹងត្រូវប្រឈមមុខដោយ

ធុរកិច្ចទាំងនេះ។ម្យ៉ាងវិញទៀត ឥរិយាបទរបស់ធុរកិច្ចនៅបរទេស អាចនឹងជះឥទ្ធិពលទៅរដ្ឋសាមីវិញ។

ការទទួលបានព័ត៌មាន៖ គោលការណ៍ណែនាំនេះកំណត់អំពីរបៀប ដែលរដ្ឋអាចផ្តល់ព័ត៌មានបានកាន់តែប្រសើរឡើង និងទាន់ពេលវេលា ទាក់ទងនឹងផលប៉ះពាល់សិទ្ធិមនុស្ស ដោយសារសកម្មភាពរបស់ធុរកិច្ច (លេខ៣)។ តម្លាភាព និងការទទួលបានព័ត៌មាន អាចជួយដល់ការសម្របសម្រួល កិច្ចពិភាក្សាគ្នា និងការចូលពាក់ព័ន្ធប្រកបដោយអត្ថន័យរវាងរដ្ឋ ធុរកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត។ បើសិនជាមានទំនាស់កើតឡើងនោះ ការផ្តល់ និងទទួលបានព័ត៌មានគ្រប់គ្រាន់ នឹងរួមចំណែកដល់ការដោះស្រាយបញ្ហានានា និងទប់ស្កាត់ទំនាស់ពីការរីករាលដាល។

ការទទួលបានដំណោះស្រាយ៖ ប្រសិនជាកើតមាននូវការរំលោភបំពានសិទ្ធិមនុស្សទាក់ទងនឹងសកម្មភាពរបស់ធុរកិច្ច រដ្ឋាភិបាលទាំងឡាយមានកាតព្វកិច្ចត្រូវធានាថា បុគ្គលទាំងឡាយដែលរងការប៉ះពាល់ទទួលបាននូវដំណោះស្រាយ ហើយគោលការណ៍ណែនាំនេះផ្តល់ក្របខ័ណ្ឌមួយ ដើម្បីជួយដល់រដ្ឋនានា (លេខ២៥ ដល់លេខ ៣១)។ រដ្ឋទាំងឡាយអាចរំលោភបំពានកាតព្វកិច្ចច្បាប់សិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ប្រសិនជាការរំលោភបំពាននោះចេញមកពីរដ្ឋខ្លួនឯង ឬ រដ្ឋខកខានមិនបានចាត់វិធានការសមស្របដើម្បីបង្ការ ស៊ើបអង្កេត ដាក់ទោសទណ្ឌ និងដោះស្រាយចំពោះអំពើរំលោភបំពានប្រព្រឹត្តដោយធុរកិច្ច។ គោលការណ៍ណែនាំនេះកំណត់អំពីវិធានការនានា ដែលរដ្ឋអាចចាត់ឡើង ដើម្បីធានាអោយ

ជនរងគ្រោះ ទៅប្រើប្រាស់បានកាន់តែប្រសើរនូវយន្តការតាមប្រព័ន្ធយុត្តិធម៌ (ក្នុងប្រព័ន្ធតុលាការ) និងយន្តការក្រៅប្រព័ន្ធតុលាការ (លេខ២៧ ដល់លេខ២៩) មានដូចជាសាលាក្តីអាជ្ញាកណ្តាល យន្តការផ្សះផ្សា ស្ថាប័នសិទ្ធិមនុស្សជាតិ និងអំប៊ុតស្មាន (អ្នកជំនាញ ឯករាជ្យ ដែលទទួល ពិនិត្យ និងតាមដានការដោះស្រាយបណ្តឹងដែលដាក់ដោយប្រជាពលរដ្ឋ)។

*សំរាប់ធុរកិច្ច៖*

<u>បទដ្ឋានសម្រាប់ការតាមដានមើល៖</u> គោលការណ៍ណែនាំនេះស្រាយបំភ្លឺបទដ្ឋានគោល សំរាប់ធុរកិច្ច នៅពេលដែលវានិយាយអំពីសិទ្ធិមនុស្ស។ គោលការណ៍ណែនាំនេះ ផ្តល់ការណែនាំដល់ធុរកិច្ចនានា ឲ្យយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌធុរកិច្ច និងបង្កើតគោលនយោបាយ និងយន្តការនានា ដើម្បីដោះស្រាយចំពោះហានិភ័យ និងផលប៉ះពាល់សិទ្ធិមនុស្ស (លេខ១១ ដល់លេខ២១)។ តាមរយៈការកំណត់បទដ្ឋានដូចគ្នា និងជាសាកលសំរាប់ធុរកិច្ចទាំងអស់ នោះវាអាចជួយឲ្យធុរកិច្ច តាមដានមើលការអនុវត្តន៍ស្របតាមបទដ្ឋានសិទ្ធិមនុស្សរបស់ខ្លួន។

<u>អត្ថប្រយោជន៍ខាងពាណិជ្ជកម្ម៖</u> ការមានជាស្រេចនូវគោលនយោបាយសិទ្ធិមនុស្ស (លេខ១៦) អាចរួមចំណែកដល់ការបង្កើនកេរ្តិ៍ឈ្មោះល្អ ដែលអាចផ្សារភ្ជាប់ទៅនឹងការរកបានទីផ្សារ អតិថិជន វិនិយោគិនកាន់តែប្រសើរឡើង និងការលក់ផលិតផលក្នុងបរិមាណខ្ពស់ថែមទៀត។ ការធ្វើឲ្យកម្មករពេញចិត្ត អាចនាំឲ្យ

សង្វាក់ផលិតកម្មមានសន្ទុះខ្លាំង ហើយធុរកិច្ចមានលទ្ធភាពទាក់ទាញ និងរក្សាកម្មករ/និយោជិតរបស់ខ្លួន។ សុវត្ថិភាពផ្គត់ផ្គង់ជាខ្សែសង្វាក់អាចបង្កើតអោយមានស្ថិរភាពដល់ការផលិត។ វាក៏អាចជួយផងដែរឲ្យការចំណាយមានប្រយោជន៍ទាក់ទងនឹងការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវលើធនធានបរិស្ថាន ក៏ដូចជាការធានាឲ្យធុរកិច្ចប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវ ធនធានធម្មជាតិដែលចាំបាច់សំរាប់ប្រតិបត្តិការរបស់ខ្លួន។

<u>ការកាត់បន្ថយហានិភ័យ</u>៖ ធុរកិច្ចទាំងឡាយមានការទទួលខុសត្រូវក្នុងការទប់ស្កាត់ និងដោះស្រាយ ផលប៉ះពាល់អវិជ្ជមាននានា (លេខ២២) ដែលខ្លួនមានជាប់ពាក់ព័ន្ធ ហើយគោលការណ៍ណែនាំនេះ ផ្តល់ជម្រើសផ្សេងៗសំរាប់ធុរកិច្ច ដើម្បីចូលរួមដោះស្រាយប្រកបដោយប្រសិទ្ធភាព (លេខ២៥ ដល់ លេខ ៣១)។ ធុរកិច្ចដែលមិនគោរពសិទ្ធិមនុស្ស ឬមិនផ្តល់អោយមានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព មានហានិភ័យខ្ពស់ដោយប្រឈមនឹងបណ្តឹងសិទ្ធិមនុស្ស ការរំខានដល់ប្រតិបត្តិការ ដោយសារតែទំនាស់នានា ឬការផ្សព្វផ្សាយព័ត៌មានអវិជ្ជមាន ដោយសារតែការពាក់ព័ន្ធជាមួយអំពើរំលោភបំពាន ហើយដែលអាចប៉ះពាល់ដល់ប្រាក់កំរៃ និងគំរាមកំហែងដល់និរន្តរភាពនៃធុរកិច្ចនោះ។ គោលការណ៍ណែនាំជួយសហគ្រាសពាណិជ្ជកម្ម គ្រប់គ្រងហានិភ័យនេះ ដោយណែនាំអំពីការដោះស្រាយតាមប្រព័ន្ធតុលាការ និងយន្តការដោះស្រាយបណ្តឹងនៅ "ថ្នាក់ប្រតិបត្តិការ" (រួមទាំង នៅថ្នាក់មូលដ្ឋាន ឬបែបមិនផ្លូវការ) ដែលអាចជាការបំពេញបន្ថែមដ៏សំខាន់ទៅនឹងយន្តការដោះស្រាយរបស់រដ្ឋ។

ការទទួលបានព័ត៌មាន៖ គោលការណ៍ណែនាំនេះកំណត់អំពីរបៀប ដែលធុរកិច្ច អាចផ្តល់ព័ត៌មាន បានកាន់តែប្រសើរឡើង និងទាន់ពេលវេលាទាក់ទងនឹងផលប៉ះពាល់សិទ្ធិមនុស្ស ដោយសារសកម្មភាពរបស់ខ្លួន (លេខ ១៦ និងលេខ ២១)។ តម្លាភាព និងការទទួលបានព័ត៌មាន អាចជួយដល់ការសម្របសម្រួលកិច្ចពិភាក្សាគ្នា និងការចូលពាក់ព័ន្ធប្រកបដោយអត្ថន័យរវាងរដ្ឋ ធុរកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត។ បើសិនជាមានទំនាស់កើតឡើង នោះការផ្តល់និងទទួលបានព័ត៌មានគ្រប់គ្រាន់ អាចជួយរួមចំណែកដល់ការដោះស្រាយបញ្ហានានា ទប់ស្កាត់ទំនាស់ពីការរីករាលដាល និងជួយកសាងទំនុកចិត្តក្នុងចំណោមអ្នកពាក់ព័ន្ធ។

### *សម្រាប់សង្គមស៊ីវិល បុគ្គល/សហគមន៍ដែលទទួលរងផលប៉ះពាល់ និងស្ថាប័នសិទ្ធិមនុស្សជាតិ៖*

ការឃ្លាំមើលប្រកបដោយការយកចិត្តទុកដាក់ខ្លាំង៖ មានការសង្ឃឹមទុកជាមុនថា ធុរកិច្ចនានាមានរួចជាស្រេចនូវ គោលនយោបាយ និងនីតិវិធីនានា ដើម្បីធានាដល់ការគោរពសិទ្ធិមនុស្ស នៅគ្រប់ប្រតិបត្តិការទាំងអស់របស់ខ្លួន។ ដោយមានកិច្ចសហការជាមួយឯកត្តបុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់ អង្គការសង្គមស៊ីវិលនានា ដើរតួនាទីដ៏សំខាន់ក្នុងការតាមឃ្លាំមើលលើសកម្មភាពនៃការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស និងការដោះស្រាយ (ការវាយតំលៃលើផលប៉ះពាល់ និងការឆ្លើយតប) របស់សហគ្រាសពាណិជ្ជកម្ម ព្រមទាំងដៃគូរបស់រដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍របស់ពួកគេ ដែលជានិច្ចកាល ធ្វើការជាដៃគូជាមួយ

ស្ថាប័នសិទ្ធិមនុស្សជាតិនានា។ គោលការណ៍ណែនាំ ចែងអំពីក្របខ័ណ្ឌនៃការយកចិត្តទុកដាក់ខ្លាំងលើសិទ្ធិមនុស្ស (លេខ ១៦ ដល់លេខ ២១) ព្រមទាំងចែងពីចំណុចយោងរួមមួយ សម្រាប់ធ្វើជាបទដ្ឋាននៃការវាយតំលៃលើផលប៉ះពាល់ ដែលអាចគាំទ្រដល់កិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗគ្នា។ គោលការណ៍ទាំងនោះក៏លើកទឹកចិត្តអោយ មានការឃ្លាំមើលជាប្រចាំលើហានិភ័យខាងសិទ្ធិមនុស្ស និងការឆ្លើយតប (តាមដាន) ការទទួលបានព័ត៌មាន (ការទាក់ទងផ្តល់ព័ត៌មានគ្នាទៅវិញទៅមក) និងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យដោយធុរកិច្ច ជាមួយនឹងក្រុមដែលរងផលប៉ះពាល់ជាសក្តានុពល។

<u>ការទទួលបានដំណោះស្រាយ</u>៖ គោលការណ៍ណែនាំនេះផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះការរកដំណោះស្រាយជូន (លេខ ២៥ ដល់លេខ ៣១) ជនរងគ្រោះនៃអំពើរំលោភបំពានសិទ្ធិមនុស្សទាក់ទងនឹងធុរកិច្ច។ គោលការណ៍ណែនាំនេះអាចជួយធានាថា នៅពេលមានអ្នកណាទទួលរងព្យសនកម្មពីសកម្មភាពរបស់ធុរកិច្ច នៅពេលនោះត្រូវមានទាំងការទទួលខុសត្រូវគ្រប់គ្រាន់ និងដំណោះស្រាយយ៉ាងមានប្រសិទ្ធភាព (តាមប្រព័ន្ធយុត្តិធម៌ និងក្រៅប្រព័ន្ធយុត្តិធម៌)។ គោលការណ៍ណែនាំទាំងនោះក៏ផ្តល់អនុសាសន៍ (លេខ ២៦) សំរាប់ជួយកាត់បន្ថយបន្ទុកនៃការប្រើប្រាស់យន្តការដោះស្រាយតាមផ្លូវតុលាការរបស់រដ្ឋ (ក្នុងរង្វង់ប្រព័ន្ធតុលាការ)។ គោលការណ៍ណែនាំក៏លើកទឹកចិត្តផងដែរដល់ការប្រើប្រាស់យន្តការដោះស្រាយវិវាទ "ថ្នាក់ប្រតិបត្តិការ" (ថ្នាក់មូលដ្ឋាន ឬបែបមិនផ្លូវការ) ( លេខ២៧ ដល់លេខ២៩) ជាជម្រើស

ផ្សេង ជំនួសឲ្យយន្តការដោះស្រាយនានារបស់រដ្ឋ មានដូចជា សាលាក្ដីអាជហុក យន្តការផ្សះផ្សា ស្ថាប័នសិទ្ធិមនុស្សជាតិ និងអំប៊ុតស្មាន។ គោលការណ៍ណែនាំនេះ ផ្ដល់នូវលក្ខខ័ណ្ឌសំរាប់យន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ អោយអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ (លេខ ៣១)។

<u>ការតស៊ូមតិ និងជំនួយបច្ចេកទេស</u>៖ គោលការណ៍ណែនាំនេះ កំណត់បទដ្ឋានរួម សម្រាប់ការប្រព្រឹត្តរបស់ធុរកិច្ច ព្រមទាំងបង្កើតនូវវេទិកាសកលមួយ សម្រាប់ការចូលរួមនៃអ្នកពាក់ព័ន្ធនានា។ គោលការណ៍ណែនាំទាំងនេះ ជាចំណុចយោងដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ សម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការរវាង សង្គមស៊ីវិល ស្ថាប័នសិទ្ធិមនុស្សជាតិនានា ព្រមទាំងបុគ្គល និង សហគមន៍ដែលរងផលប៉ះពាល់ជាមួយរដ្ឋ និងធុរកិច្ច។ គោលការណ៍ណែនាំទាំងនេះ អាចផ្ដល់ជាមូលដ្ឋានសម្រាប់ការឃ្លាំមើល និងរាយការណ៍ពីការអនុវត្តន៍នៃធុរកិច្ច ក៏ដូចជាដើរតួជាវេទិកាសំរាប់ផ្ដល់ការប្រឹក្សាបច្ចេកទេស។ ដោយសារមានធុរកិច្ចជាច្រើន ងាកទៅរករដ្ឋាភិបាលដើម្បីទទួលបាននូវ យោបល់ ការណែនាំ និងសេចក្ដីរំពឹងទុកច្បាស់លាស់សំរាប់ការប្រព្រឹត្តទៅនៃធុរកិច្ច របស់ខ្លួន ដូច្នេះសង្គមស៊ីវិល បុគ្គល/សហគមន៍រងផលប៉ះពាល់ និងស្ថាប័នសិទ្ធិមនុស្សជាតិ អាចដើរតួនាទីគាំទ្រដល់ផ្នែកនេះ។

***សម្រាប់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍៖***

ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា រួមទាំងស្ថាប័នហិរញ្ញវត្ថុ

ពហុភាគី គឺជាបណ្តាញនាំយកការគាំទ្រជំនួយ និងការឧបត្ថម្ភចូលមកក្នុងប្រទេសដែលពួកគេធ្វើប្រតិបត្តិការ។ ដៃគូរបស់ពួកគេមានស្ថាប័នរដ្ឋ សង្គមស៊ីវិល សហគមន៍ ឯកត្តបុគ្គល និងភាគីទីបីផ្សេងៗទៀត។ ជានិច្ចកាល ពួកគេជួលក្រុមហ៊ុនពិគ្រោះយោបល់ឯកជន និងទីភ្នាក់ងារមកពីខាងក្រៅ ដើម្បីជួយអនុវត្តការងាររបស់ពួកគេ នៅពេលដែលពួកគេត្រូវការជំនាញ និងកំលាំងពលកម្មបន្ថែម។ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ មានគណនេយ្យភាពចំពោះច្បាប់នៃរដ្ឋសាមីរៀងៗខ្លួនរបស់ពួកគេ ដែលប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ពួកគេក៏ប្រតិបត្តិ ក្រោមការរ៉ាប់រងរបស់រដ្ឋដែលទទួលពួកគេផងដែរ ដែលរដ្ឋទាំងនេះក៏ត្រូវតែប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិផងដែរ។ សរុបមក ពួកគេគឺជាភាគីទីបីដែលស្ថិតក្រោមក្របខ័ណ្ឌអន្តរជាតិរបស់ធុរកិច្ច និងសិទ្ធិមនុស្ស ហើយពួកគេអាចទទួលខុសត្រូវតាមច្បាប់ ប្រសិនបើពួកគេបំពេញទំនួលខុសត្រូវរបស់ខ្លួនមិនបានត្រឹមត្រូវ។ ពួកគេគួរតែអនុវត្តការត្រួតពិនិត្យមើលលើដៃគូរបស់ខ្លួន និងលើកទឹកចិត្តដល់ដៃគូសាធារណៈ និងដៃគូឯកជន អោយយកចិត្តទុកដាក់ខ្ពស់លើសិទ្ធិមនុស្ស ។ លើសពីនេះទៀត ពួកគេមានការទទួលខុសត្រូវចំពោះការមិនធ្វើអោយចុះខ្សោយដល់លទ្ធភាពបំពេញការទទួលខុសត្រូវរបស់អ្នកដែលទទួលបានផលប្រយោជន៍នោះដែរ ។ បន្ថែមពីលើការបំពេញទៅតាមបទដ្ឋានទាំងអស់ ដែលមាននៅក្នុងគោល ការណ៍ណែនាំនេះ វាក៏អាចជាតួនាទីរបស់ពួកគេផងដែរក្នុងការជួយដល់អ្នកពាក់ព័ន្ធនានា អនុវត្តគោលការណ៍ណែនាំនេះ (លេខ១០) ។

## V. ព័ត៌មានបន្ថែម

គោលការណ៍ណែនាំ មាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងរបាយការណ៍ឆ្នាំ២០១១ របស់អ្នកតំណាងពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស (A/HRC/17/31) ដែលអាចរកបាននៅ៖

http://www2.ohchr.org/english/bodies/hrcouncil/docs/17session/A.HRC.17.31_en.pdf

របាយការណ៍ផ្សេងៗទៀតមកពីអ្នកតំណាងពិសេសនៃអគ្គលេខាធិការសហប្រជាជាតិស្តីពីបញ្ហា សិទ្ធិមនុស្ស និងសាជីវកម្មឆ្លងដែន និងសហគ្រាសពាណិជ្ជកម្មផ្សេងៗទៀត អាចរកបាននៅ៖

http://www.ohchr.org/EN/Issues/TransnationalCorporations/Pages/Reports.aspx

របាយការណ៍មួយចំនួនដែលមាននូវប្រវត្តិទាក់ទងនឹងគោលការណ៍ណែនាំ រួមមាន៖

- *ការការពារ ការគោរព និងដំណោះស្រាយ៖ ក្របខណ្ឌសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្ស* (A/HRC/8/5)
- *របាយការណ៍របស់អ្នកតំណាងពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ឆ្នាំ២០១០* (A/HRC/14/27)
- *របាយការណ៍របស់អ្នកតំណាងពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ឆ្នាំ២០០៩* (A/HRC/11/13)

របាយការណ៍មានអត្ថប្រយោជន៍ពាក់ព័ន្ធមួយចំនួនទៀតរួមមាន៖

- *គោលការណ៍សម្រាប់កិច្ចសន្យាដែលមានការទទួលខុសត្រូវ៖ បញ្ចូលការគ្រប់គ្រង ហានិភ័យសិទ្ធិមនុស្សចូលទៅក្នុងកិច្ចចរចារធ្វើកិច្ចសន្យា រវាងរដ្ឋ និងអ្នកវិនិយោគ - គោលការណ៍ណែនាំសម្រាប់ការចរចារ* (A/HRC/17/31/Add.3)
- *កាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់អោយមាននូវការទទួលបានដំណោះស្រាយ ចំពោះ អំពើរំលោភបំពានសិទ្ធិមនុស្សប្រព្រឹត្តឡើងដោយភាគីទីបី រួមទាំង ធុរកិច្ច* (A/HRC/17/31/Add.1)

ប្រភពផ្សេងៗ៖

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ - បញ្ជីឈ្មោះឧបករណ៍ស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស៖

http://www.ohchr.org/EN/Issues/Business/Pages/Tools.aspx

គ្លូបលកំផែក របស់អង្គការសហប្រជាជាតិ៖ គោលការណ៍ដប់៖

http://www.unglobalcompact.org/AboutTheGC/TheTenPrinciples/index.html

មជ្ឈមណ្ឌលធនធានស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស៖ web portal[៦] នៃ តំណាងពិសេស៖

http://www.business-humanrights.org/SpecialRepPortal/Home

[៦] នេះមិនមែនជាវិបសាយរបស់អង្គការសហប្រជាជាតិនោះទេ។

## ឧបសម្ព័ន្ធ៖ ច្បាប់ និងបទប្បញ្ញត្តិមួយចំនួនរបស់កម្ពុជាដែលអនុវត្តបានចំពោះធុរកិច្ច និងសិទ្ធិមនុស្ស[២]

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

## ច្បាប់ស្ដីពី ដីធ្លី៖

ច្បាប់ភូមិបាល

- ច្បាប់ស្ដីពី សម្បទាន
- អនុក្រឹត្យស្ដីពី ការគ្រប់គ្រងដីរដ្ឋ
- អនុក្រឹត្យស្ដីពី សម្បទានដីសេដ្ឋកិច្ច
- អនុក្រឹត្យស្ដីពី វិធាន និងនីតិវិធីស្ដីពីការធ្វើអនុយោគនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងស្ថាប័នសាធារណៈ
- ប្រកាសរួមស្ដីពី ការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីទាក់ទងនឹងទំនាស់ដីធ្លី

## ច្បាប់ស្ដីពីព្រៃឈើ

- ច្បាប់ស្ដីពី ព្រៃឈើ
- អនុក្រឹត្យស្ដីពី ការគ្រប់គ្រងព្រៃសម្បទាន
- អនុក្រឹត្យស្ដីពី ការគ្រប់គ្រងព្រៃសហគមន៍
- អនុក្រឹត្យស្ដីពី ការបង្កើតនីតិវិធីធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីដីព្រៃអចិន្ត្រៃយ៍

[២] តារាងនេះមិនគ្របដណ្ដប់ច្បាប់ទាំងអស់នោះទេ ហើយអាចផ្លាស់ប្ដូរនាពេលខាងមុខ។

## ច្បាប់ស្តីពីជលផល

- ច្បាប់ស្តីពី ជលផល
- អនុក្រឹត្យស្តីពី សហគមន៍នេសាទ ដែលបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី

## ច្បាប់ស្តីពីធនធានទឹក

- ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា

## ច្បាប់ស្តីពីថាមពល

- ច្បាប់ស្តីពី អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

## ច្បាប់ស្តីពីការវិនិយោគ

- ច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពី វិសោធនកម្មលើច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## ច្បាប់ស្តីពីធនធានរ៉ែ

- ច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- អនុក្រឹត្យស្តីពី ការកំណត់គោលការណ៍វិនិយោគនៃធនធានរ៉ែ

## ច្បាប់ស្តីពីតំបន់ការពារ

- ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- ព្រះរាជក្រឹត្យស្តីពី តំបន់ការពារធម្មជាតិ

## ច្បាប់ស្តីពីបរិស្ថាន

- ច្បាប់ស្តីពី កិច្ចការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- អនុក្រឹត្យស្តីពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## ច្បាប់ស្តីពីការងារ

- ច្បាប់ស្តីពី ការងារ

## បទប្បញ្ញត្តិស្តីពីប្រេងកាត

- បទប្បញ្ញត្តិប្រេងកាត
- សេចក្តីសំរេច ស្តីពី ការកែសំរួលបទបញ្ញត្តិប្រេងកាត

## ច្បាប់ស្តីពីពាណិជ្ជកម្ម

- ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម
- ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ច្បាប់ផ្សេងៗ

- ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- ច្បាប់ស្តីពី គ្រឹស្ថានធនាគារ និងហិរញ្ញវត្ថុ
- ច្បាប់ស្តីពី សារពើពន្ធ
- ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា

# ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិ
# ស្តីពី
# "ការការពារ ការគោរព និងដំណោះស្រាយ"

## គោលការណ៍ទូទៅ

គោលការណ៍ណែនាំទាំងនេះមានមូលដ្ឋានលើការទទួលស្គាល់ថា៖

(ក) រដ្ឋមានកាតព្វកិច្ចស្រាប់ក្នុងការគោរព ការពារ និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានា

(ខ) សហគ្រាសពាណិជ្ជកម្ម ដែលមានតួនាទីជាអង្គភាពឯកទេសក្នុងសង្គម បំពេញមុខងារឯកទេស តម្រូវឲ្យអនុវត្តស្របតាមច្បាប់ជាធរមាន និងគោរពសិទ្ធិមនុស្ស

(គ) សេចក្តីត្រូវការឲ្យសិទ្ធិ និងកាតព្វកិច្ច មានព្រមគ្នាជាមួយនឹងការដោះស្រាយដ៏សមស្រប និងមានប្រសិទ្ធិភាព នៅពេលមានការរំលោភបំពាន។

---

[៣] ការបកប្រែជាភាសាខ្មែរនៃគោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្សនេះមិនបានបញ្ចូលសេចក្តីអត្ថាធិប្បាយ

គោលការណ៍ណែនាំទាំងនេះ ត្រូវយកទៅអនុវត្តនៅគ្រប់រដ្ឋ និងសហគ្រាសពាណិជ្ជកម្មទាំងអស់ ទាំងសាជីវកម្មឆ្លងដែន និងសហគ្រាសផ្សេងៗទៀត ដោយមិនគិតពី ទំហំ វិស័យ ទីតាំង ប្រភេទ ម្ចាស់កម្មសិទ្ធិ និងរចនាសម្ព័ន្ធឡើយ។

គោលការណ៍ណែនាំទាំងនេះគួរត្រូវបានយល់ដឹងថា ជាគោលការណ៍មានលក្ខណៈជាក់ស្តែងទាំងស្រុង និងគួរតែត្រូវបានអាន ទោះជាដោយឯកឯងក្តី និងជារួមក្តី ដោយយល់ពីគោលបំណងនៃការពង្រឹងបទដ្ឋាននានា និងការអនុវត្តន៍ទាក់ទងនឹងធុរកិច្ចនិងសិទ្ធិមនុស្សរបស់គោលការណ៍ទាំងនេះ ដើម្បីជាប្រយោជន៍ឈានទៅសម្រេចបានលទ្ធផលជាក់ស្តែងសម្រាប់បុគ្គល និងសហគមន៍នានាដែលរងការប៉ះពាល់ ហើយអាស្រ័យហេតុនេះ វានឹងរួមចំណែកផងដែរដល់សកលភាវូនីយកម្មប្រកបដោយនិរន្តរភាពខាងសង្គម។

គ្មានចំណុចណាមួយក្នុងគោលការណ៍ណែនាំនេះ ត្រូវបានយល់ថា ជាការបង្កើតកាតព្វកិច្ចថ្មីក្រោមច្បាប់អន្តរជាតិនោះទេ ឬជាការកំហិត ឬធ្វើឲ្យចុះខ្សោយដល់កាតព្វកិច្ចតាមច្បាប់ ដែលរដ្ឋបានប្រកាន់យក ឬស្ថិតក្រោមច្បាប់អន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សនោះទេ។

គោលការណ៍ណែនាំទាំងនេះ គួរតែត្រូវបានអនុវត្តដោយគ្មានការរើសអើងដោយមានការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិ និងសេចក្តីត្រូវការ ព្រមទាំងឧបសគ្គដែលប្រឈមដោយបុគ្គល ក្រុម ឬក្រុមប្រជាពលរដ្ឋដែលមានកំរិតហានិភ័យខ្ពស់ក្នុងការក្លាយខ្លួនទៅជាជនងាយរងគ្រោះ ឬជនត្រូវគេផាត់ចេញ និងដោយមានការគិតគូរដ៏ត្រឹមត្រូវដល់ហានិភ័យផ្សេងៗគ្នាដែលស្ត្រី និងបុរសអាចនឹងប្រឈម។

# I. រដ្ឋមានភារកិច្ចការពារសិទ្ធិមនុស្ស

## ក. គោលការណ៍ជាមូលដ្ឋាន

១. រដ្ឋត្រូវតែការពារប្រឆាំងនឹង ការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្ត ដោយភាគីទីបី រាប់បញ្ចូលទាំងសហគ្រាសពាណិជ្ជកម្មនៅក្នុង ដែនដី និង/ឬ ដែនសមត្ថកិច្ចរបស់ខ្លួន។ កិច្ចការនេះតំរូវឲ្យរដ្ឋ ចាត់វិធានការសមស្របនានា ដើម្បីបង្ការ ស៊ើបអង្កេត ដាក់ ទណ្ឌកម្ម និងដោះស្រាយចំពោះការរំលោភបែបនេះ តាមរយៈ គោលនយោបាយ ច្បាប់ បទបញ្ញា និងការជំនុំជម្រះតាមផ្លូវ តុលាការ ប្រកបដោយប្រសិទ្ធិភាព។

២. រដ្ឋគួរកំណត់ការរំពឹងទុកឲ្យជាក់លាក់ថា សហគ្រាសពាណិជ្ជ កម្មទាំងអស់ ដែលមានទីតាំងនៅក្នុងដែនដី និង/ឬ ដែនសមត្ថ កិច្ចរបស់ខ្លួន គោរពសិទ្ធិមនុស្សនៅក្នុងគ្រប់ប្រតិបត្តិការទាំង អស់របស់ពួកគេ។

## ខ. គោលការណ៍ប្រតិបត្តិការ

### *មុខងារទូទៅរបស់រដ្ឋក្នុងការបង្កើតច្បាប់ និងគោលនយោបាយ*

៣. ដើម្បីបំពេញភារកិច្ចការពាររបស់ខ្លួន រដ្ឋគួរតែៈ

(ក) អនុវត្តច្បាប់នានាដែលមានគោលបំណង ឬមានអនុភាព តំរូវឲ្យសហគ្រាសពាណិជ្ជកម្មនានា គោរពសិទ្ធិមនុស្ស និងធ្វើការវាយតំលៃតាមកាលកំណត់នូវភាពគ្រប់គ្រាន់នៃ

ច្បាប់ទាំងនោះព្រមទាំងដោះស្រាយចំពោះបញ្ហាចន្លោះប្រហោងណាមួយរបស់ច្បាប់

(ខ) ធានាថាច្បាប់ និងគោលនយោបាយផ្សេងៗ ដែលគ្រប់គ្រងការបង្កើត និងការប្រព្រឹត្តទៅនៃសហគ្រាសពាណិជ្ជកម្មនានា ដូចជាច្បាប់សាជីវកម្មពុំបង្កការរិតត្បិត ប៉ុន្តែផ្ដល់លទ្ធភាពដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស

(គ) ផ្ដល់ការណែនាំដ៏មានប្រសិទ្ធិភាពដល់សហគ្រាសពាណិជ្ជកម្មនានាអំពីរបៀបគោរពសិទ្ធិមនុស្សនៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់របស់ពួកគេ

(ឃ) លើកទឹកចិត្ត និងប្រសិនបើសមស្រប តំរូវឲ្យសហគ្រាសពាណិជ្ជកម្មនានាប្រាស្រ័យទាក់ទងអំពីរបៀបដែលពួកគេដោះស្រាយលើផលប៉ះពាល់ខាងសិទ្ធិមនុស្សនានា។

## សហគ្រាសរដ្ឋ

៤. រដ្ឋនានា គួរចាត់វិធានការបន្ថែម ដើម្បីការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស ដោយសហគ្រាសពាណិជ្ជកម្ម ដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬគ្រប់គ្រងដោយរដ្ឋ ឬដែលទទួលការគាំទ្រ និងសេវាជាសារវន្តពីទីភ្នាក់ងារនានារបស់រដ្ឋ ដូចជា ក្រុមហ៊ុនធានារ៉ាប់រងការវិនិយោគ និងក្រុមហ៊ុន ឬទីភ្នាក់ងារធានារ៉ាប់រងការវិនិយោគផ្លូវការនានា ដោយរួមបញ្ចូល ប្រសិនបើសមស្របនូវការតំរូវឲ្យធ្វើការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស។

៥. រដ្ឋគួរតែពិនិត្យមើលឲ្យគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន នៅពេលដែលពួកគេចុះកិច្ចសន្យា

ជាមួយ ឬធ្វើច្បាប់សម្រាប់សហគ្រាសពាណិជ្ជកម្ម ក្នុងការផ្តល់សេវានានា ដែលអាចប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិមនុស្ស ។

៦. រដ្ឋគួរតែជំរុញសហគ្រាសពាណិជ្ជកម្មនានា ដែលខ្លួនធ្វើពាណិជ្ជកម្មជាមួយ ឲ្យគោរពសិទ្ធិមនុស្ស។

## គាំទ្រដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្សនៅក្នុងតំបន់នានាដែលមានវិវាទ

៧. ដោយសារតែហានិភ័យនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមានកំរិតខ្ពស់នៅក្នុងតំបន់នានាដែលមានវិវាទ រដ្ឋគួរតែជួយធានាថា សហគ្រាសពាណិជ្ជកម្មនានា ដែលធ្វើប្រតិបត្តិការនៅក្នុងបរិបទទាំងនោះ មិនពាក់ព័ន្ធនឹងការរំលោភបែបនោះ រួមមាន៖

(ក) ចូលរួមជាមួយសហគ្រាសពាណិជ្ជកម្ម តាំងពីដំណាក់កាលដំបូងបំផុត តាមតែអាចធ្វើទៅបាន ដើម្បីជួយពួកគេក្នុងការកំណត់ បង្ការ និងកាត់បន្ថយហានិភ័យទាក់ទងនឹងសិទ្ធិមនុស្ស ដោយសារសកម្មភាពរបស់ពួកគេ និងទំនាក់ទំនងធុរកិច្ច

(ខ) ផ្តល់ជំនួយគ្រប់គ្រាន់ ដល់សហគ្រាសពាណិជ្ជកម្ម ក្នុងការវាយតំលៃ និងដោះស្រាយចំពោះហានិភ័យកំរិតខ្ពស់នៃការរំលោភបំពាន ដោយត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះ ការរំលោភបំពានខាងផ្លូវភេទ និងការរំលោភផ្អែកលើយេនឌ័រ

(គ) បដិសេធមិនផ្តល់ការគាំទ្រ និងសេវាសាធារណៈនានាចំពោះសហគ្រាសពាណិជ្ជកម្មដែលមានជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងបដិសេធមិនធ្វើសហ

ប្រតិបត្តិការនៅក្នុងការដោះស្រាយស្ថានការណ៍នោះ

(ឃ) ធានាថា គោលនយោបាយ ច្បាប់ បទបញ្ញា និងវិធានការអនុវត្តន៍នាពេលបច្ចុប្បន្នរបស់ពួកគេ មានប្រសិទ្ធិភាពក្នុងការដោះស្រាយហានិភ័យ នៃការជាប់ពាក់ព័ន្ធរបស់ធុរកិច្ចនៅក្នុងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។

## ធានាគោលនយោបាយមានភាពស៊ីសង្វាក់គ្នា

៨. រដ្ឋគួរតែធានាថា អង្គភាព និង ទីភ្នាក់ងាររបស់រដ្ឋាភិបាល និងស្ថាប័នរដ្ឋនានា ដែលមានសមត្ថកិច្ចលើការអនុវត្តន៍របស់ធុរកិច្ច មានការយល់ដឹង និងប្រកាន់តាមកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរពសិទ្ធិមនុស្ស នៅពេលដែលបំពេញអាណត្តិរៀងៗខ្លួនរបស់ពួកគេ ដោយរួមបញ្ចូលទាំងការផ្តល់ដល់ពួកគេនូវព័ត៌មាន ការបណ្តុះបណ្តាល និងការគាំទ្រដែលពាក់ព័ន្ធនានា។

៩. រដ្ឋគួរតែរក្សាបរិយាកាសគោលនយោបាយក្នុងស្រុកគ្រប់គ្រាន់ដើម្បីបំពេញ តាមកាតព្វកិច្ចសិទ្ធិមនុស្សនៅពេលដែលអនុវត្តទៅតាមទិសដៅនូវគោលនយោបាយ ទាក់ទងនឹងធុរកិច្ចជាមួយរដ្ឋ ឬសហគ្រាសពាណិជ្ជកម្មផ្សេងៗ ឧទាហរណ៍ តាមរយៈសន្ធិសញ្ញា ឬកិច្ចសន្យាវិនិយោគនានា។

១០. នៅពេលចូលជាសមាជិកនៃស្ថាប័នពហុភាគីដែលដោះស្រាយបញ្ហាទាក់ទងនឹងធុរកិច្ច រដ្ឋគួរតែៈ

(ក) ស្វះស្វែងធានាថា ស្ថាប័នទាំងនោះមិនរិតត្បិតលទ្ធភាពនៃរដ្ឋជាសមាជិករបស់ខ្លួន ក្នុងការបំពេញភារកិច្ច

ការពារ និងមិនរារាំងសហគ្រាសពាណិជ្ជកម្មនានា ពីការគោរពសិទ្ធិមនុស្ស

(ខ) លើកទឹកចិត្តស្ថាប័នទាំងនោះ នៅក្នុងវង្វង់អាណត្តិ និងសមត្ថភាពរៀងៗខ្លួនរបស់ពួកគេ ឲ្យជំរុញដល់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស និងប្រសិនបើមានការស្នើសុំជួយដល់រដ្ឋក្នុងការបំពេញភារកិច្ចការពារប្រឆាំងការរំលោភសិទ្ធិមនុស្សរបស់សហគ្រាសពាណិជ្ជកម្ម រួមបញ្ចូលទាំងតាមរយៈ ជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងលើកកំពស់ការយល់ដឹង

(គ) ទាញចេញពីគោលការណ៍ណែនាំទាំងនេះ លើកស្ទួយការយល់ដឹងទាំងអស់គ្នា និងលើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការគ្រប់គ្រងធុរកិច្ច និងការប្រឈមខាងសិទ្ធិមនុស្ស។

## II. ទំនួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស

### ក. គោលការណ៍ជាមូលដ្ឋាន

១១. សហគ្រាសពាណិជ្ជកម្ម គួរតែគោរពសិទ្ធិមនុស្ស។ នេះមានន័យថា ពួកគេគួរតែជៀសវាងការបំពានលើសិទ្ធិមនុស្សរបស់អ្នកដទៃ និងគួរតែដោះស្រាយការប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរដែលពួកគេមានការពាក់ព័ន្ធ។

១២. ទំនួលខុសត្រូវរបស់សហគ្រាសពាណិជ្ជកម្ម ក្នុងការគោរពសិទ្ធិមនុស្ស សំដៅលើសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់

ជាអន្តរជាតិដោយត្រូវយល់ដឹងជាអប្បបរមាយ៉ាងហោចណាស់ នូវសិទ្ធិនានា ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង គោលការណ៍នានា ដែលពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋាន ដូចមានចែងនៅក្នុងសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិ ស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ ។

១៣. ទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សតំរូវថា សហគ្រាសពាណិជ្ជកម្មៈ

(ក) ជៀសវាងការបង្ក ឬរួមចំណែកធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស តាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ និងដោះស្រាយការប៉ះពាល់ទាំងនោះ នៅពេលដែលវាកើតឡើង

(ខ) ស្វះស្វែងបង្ការ ឬកាត់បន្ថយការប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស ដែលទាក់ទងដោយផ្ទាល់នឹងប្រតិបត្តិការ ផលិតផល ឬសេវារបស់ពួកគេ ឬដោយទំនាក់ទំនងខាងធុរកិច្ចរបស់ពួកគេ ទោះបីជាពួកគេពុំបានរួមចំណែកក្នុងការប៉ះពាល់ទាំងនោះក្តី។

១៤. ទំនួលខុសត្រូវនៃសហគ្រាសពាណិជ្ជកម្ម ក្នុងការគោរពសិទ្ធិមនុស្ស អនុវត្ត ចំពោះគ្រប់សហគ្រាសទាំងអស់ ដោយមិនគិតពីទំហំ វិស័យ បរិបទប្រតិបត្តិការ កម្មសិទ្ធ និងរចនាសម្ព័ន្ធរបស់ពួកគេ។ ទោះជាដូច្នោះក៏ដោយ វិសាលភាព និងភាពស្មុគស្មាញនៃវិធីសាស្ត្រដែលសហគ្រាសនានាប្រើប្រាស់ ដើម្បីបំពេញការទទួលខុសត្រូវនោះអាចមានភាពខុសៗគ្នា អាស្រ័យទៅតាមកត្តាទំហំ វិស័យ បរិបទ ប្រតិបត្តិការ កម្មសិទ្ធ និងរចនា

សម្ព័ន្ធនៃសហគ្រាសពាណិជ្ជកម្ម ព្រមទាំងជាមួយភាពធ្ងន់ធ្ងរនៃការប៉ះពាល់សិទ្ធិមនុស្សរបស់សហគ្រាសនោះ។

១៥. ដើម្បីបំពេញតាមទំនួលខុសត្រូវគោរពសិទ្ធិមនុស្សរបស់ខ្លួន សហគ្រាសពាណិជ្ជកម្ម គួររៀបចំបង្កើតគោលនយោបាយ និងដំណើរការប្រតិបត្តិការសមស្របទៅតាមទំហំ និងកាលៈទេសៈរបស់ខ្លួនដែលរួមមាន៖

(ក) ការប្តេជ្ញាចិត្តខាងគោលនយោបាយក្នុងការបំពេញទំនួលខុសត្រូវ គោរពសិទ្ធិមនុស្សរបស់ពួកគេ

(ខ) ដំណើរការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស ដើម្បីកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀបដែលពួកគេដោះស្រាយរាល់ការប៉ះពាល់នានារបស់ខ្លួនលើសិទ្ធិមនុស្ស

(គ) ដំណើរការផ្តល់លទ្ធភាពដល់ការដោះស្រាយចំពោះការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលពួកគេបង្ក ឬដែលពួកគេបានរួមចំណែក។

## ខ. គោលការណ៍ប្រតិបត្តិការ

## ការប្តេជ្ញាចិត្តខាងគោលនយោបាយ

១៦. ជាមូលដ្ឋានសម្រាប់ប្រកាន់ខ្ជាប់ទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្សរបស់ខ្លួន សហគ្រាសពាណិជ្ជកម្មគួរតែបង្ហាញនូវការប្តេជ្ញារបស់ខ្លួន ក្នុងការបំពេញតាមទំនួលខុសត្រូវនេះ តាមរយៈសេចក្តីថ្លែងការណ៍នៃគោលនយោបាយដែល៖

(ក) ត្រូវបានឯកភាពដោយថ្នាក់ដឹកនាំកំរិតខ្ពស់បំផុតនៃសហគ្រាសពាណិជ្ជកម្ម

(ខ) ត្រូវបានជូនដំណឹងដោយអ្នកជំនាញការផ្ទៃក្នុង និង/ឬពីខាងក្រៅ ដែលពាក់ព័ន្ធនានា

(គ) ចែងអំពីការរំពឹងទុកនៃការគោរពសិទ្ធិមនុស្សរបស់សហគ្រាសសម្រាប់បុគ្គលិក ដៃគូធុរកិច្ច និងភាគីទីបីផ្សេងៗទៀតដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ប្រតិបត្តិការ ផលិតផល ឬសេវារបស់ខ្លួន

(ឃ) អាចរកបានជាសាធារណៈ និងត្រូវបានផ្សព្វផ្សាយទាំងខាងក្នុង និងខាងក្រៅទៅដល់បុគ្គលិក ដៃគូធុរកិច្ច និងភាគីទីបីដែលពាក់ព័ន្ធទាំងអស់

(ង) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការ ដែលចាំបាច់ដើម្បីបញ្ជ្រាបសេចក្តីថ្លែងការណ៍នោះនៅទូទាំងសហគ្រាសពាណិជ្ជកម្ម។

## ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស

១៧. ដើម្បីកំណត់ បង្ការ កាត់បន្ថយ និងមានគណនេយ្យភាពចំពោះរបៀប ដែលពួកគេដោះស្រាយចំពោះការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មទាំងអស់ គួរតែធ្វើការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស។ ដំណើរការនោះគួរតែ រួមបញ្ចូលការវាយតំលៃអំពីផលប៉ះពាល់ជាក់ស្តែង និងជាសក្តានុពលលើសិទ្ធិមនុស្ស ការបូកបញ្ចូលនិងចាត់វិធានការចំពោះការរកឃើញ ការតាមដានការឆ្លើយតប និងការប្រាស្រ័យទាក់ទងលើរបៀបដោះស្រាយការប៉ះពាល់ទាំងនោះ។ ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិ

មនុស្ស៖

(ក) គួរតែគ្របដណ្តប់លើការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ដែលសហគ្រាសពាណិជ្ជកម្មអាចបង្ក ឬរួមចំណែកបង្ក តាមរយៈសកម្មភាពផ្ទាល់របស់ខ្លួន ឬអាចមានជាប់ទាក់ទង ដោយផ្ទាល់នឹងប្រតិបត្តិការ ផលិតផល ឬសេវារបស់ខ្លួន ឬ ដោយទំនាក់ទំនងខាងធុរកិច្ចរបស់ខ្លួន

(ខ) នឹងមានលក្ខណៈខុសៗគ្នា អាស្រ័យលើភាពស្មុគស្មាញទៅ តាមទំហំ នៃសហគ្រាសពាណិជ្ជកម្មនោះ ហានិភ័យនៃការ ប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ព្រមទាំងបរិយាកាស និង បរិបទនៃប្រតិបត្តិការរបស់សហគ្រាសនោះ

(គ) គួរតែធ្វើជាបន្តបន្ទាប់ ដោយទទួលស្គាល់ថា ហានិភ័យខាង សិទ្ធិមនុស្ស អាចប្រែប្រួលពីពេលមួយទៅពេលមួយ ខណៈ ដែលប្រតិបត្តិការ និងបរិបទប្រតិបត្តិការរបស់សហគ្រាស ពាណិជ្ជកម្មចេះតែវិវត្តទៅមុខ។

១៨. ដើម្បីវាស់ស្ទង់ហានិភ័យខាងសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្ម គួរតែកំណត់ និងវាយតំលៃលើការប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជា សក្តានុពលណាមួយលើសិទ្ធិមនុស្ស ដែលពួកគេអាចជាប់ពាក់ព័ន្ធ តាមរយៈសកម្មភាពផ្ទាល់របស់ពួកគេ ឬជាលទ្ធផលនៃទំនាក់ទំនង ខាងធុរកិច្ចរបស់ពួកគេ។ ដំណើរការនេះគួរតែ៖

(ក) យកចេញមកពីជំនាញសិទ្ធិមនុស្សមាននៅផ្ទៃក្នុង និង/ឬ មកពីខាងក្រៅដែលឯករាជ្យ

(ខ) រួមបញ្ចូលការពិគ្រោះយោបល់ដ៏មានអត្ថន័យ ជាមួយក្រុម ដែលរងការប៉ះពាល់ជាសក្តានុពល និងអ្នកពាក់ព័ន្ធផ្សេងៗ

ទៀត សមស្របទៅតាមទំហំនៃសហគ្រាសពាណិជ្ជកម្ម នោះ ព្រមទាំងតាមបរិបទ និងបរិយាកាសនៃប្រតិបត្តិការ របស់ខ្លួន។

១៩. ដើម្បីបង្ការ និងកាត់បន្ថយការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានា គួរតែធ្វើសមាហរណកម្មទៅក្នុងគ្រប់មុខងារ និងដំណើរការផ្ទៃក្នុងដែលពាក់ព័ន្ធទាំងអស់នូវការរកឃើញនានាបានមកពីការវាយតំលៃផលប៉ះពាល់របស់ខ្លួន និងចាត់វិធានការសមស្រប។

(ក) ការធ្វើសមាហរណកម្មដ៏មានប្រសិទ្ធិភាពតំរូវថា៖

(i) ទំនួលខុសត្រូវសម្រាប់ដោះស្រាយការប៉ះពាល់ត្រូវផ្តល់ភារកិច្ចទៅឲ្យកំរិត និងមុខងារប្រតិបត្តិការដែលសមស្រប នៅក្នុងសហគ្រាសពាណិជ្ជកម្មនោះ

(ii) ការធ្វើការសម្រេចចិត្តផ្ទៃក្នុង ការបែងចែកថវិកា និងដំណើរការត្រួតពិនិត្យមើល ផ្តល់លទ្ធភាពឲ្យមានការឆ្លើយតបដ៏មានប្រសិទ្ធិភាពចំពោះការប៉ះពាល់ទាំងអស់ នោះ។

(ខ) ចំណាត់ការសមស្របនឹងមានភាពខុសៗគ្នាទៅតាម៖

(i) ថាតើសហគ្រាសពាណិជ្ជកម្មបង្ក ឬរួមចំណែកបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរ ឬថាតើសហគ្រាសពាណិជ្ជកម្មមានជាប់ពាក់ព័ន្ធទាំងស្រុង ដោយសារតែការប៉ះពាល់នោះជាប់ទាក់ទងដោយផ្ទាល់ទៅនឹង ប្រតិបត្តិការផលិតផល ឬសេវារបស់ខ្លួន ឬដោយទំនាក់ទំនងខាង

ធុរកិច្ចរបស់ខ្លួន

(ii) វិសាលភាពនៃឥទ្ធិពលរបស់សហគ្រាសក្នុងការដោះស្រាយការប៉ះពាល់ធ្ងន់ធ្ងរ។

២០. ដើម្បីបញ្ជាក់ថា តើការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្សកំពុងត្រូវបានដោះស្រាយ សហគ្រាសពាណិជ្ជកម្មនានាគួរតែតាមដានប្រសិទ្ធិភាពនៃការឆ្លើយតបរបស់ពួកគេ។ ការតាមដានគួរតែះ

(ក) ផ្អែកលើរង្វាស់ប្រកបដោយបរិមាណ និងគុណភាពសមស្រប

(ខ) ផ្អែកលើប្រតិកម្មដែលបានមកពីទាំងប្រភពផ្ទៃក្នុង និងខាងក្រៅ រួមទាំងអ្នកពាក់ព័ន្ធដែលរងការប៉ះពាល់នានាផងដែរ។

២១. ដើម្បីមានគណនេយ្យភាព ចំពោះរបៀបដែលពួកគេដោះស្រាយការប៉ះពាល់លើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានា គួរតែរៀបចំជូនដំណឹងអំពីបញ្ហានេះ ទៅខាងក្រៅ ជាពិសេសនៅពេលដែលកង្វល់នានាត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធដែលរងការប៉ះពាល់ ឬដោយតំណាងរបស់ពួកគេ។ សហគ្រាសពាណិជ្ជកម្មដែលប្រតិបត្តិការ ឬបរិបទប្រតិបត្តិការរបស់ខ្លួន បង្កហានិភ័យឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិមនុស្ស គួរតែរាយការណ៍ជាផ្លូវការអំពីរបៀបដែលខ្លួនដោះស្រាយការប៉ះពាល់ទាំងនោះ។ នៅក្នុងគ្រប់ព្រឹត្តិការណ៍ទាំងអស់ ការជូនដំណឹងនោះគួរតែះ

(ក) ជាទម្រង់មួយ និងមានភាពញឹកញាប់ ដែលវាឆ្លុះបញ្ចាំងអំពីការប៉ះពាល់លើសិទ្ធិមនុស្សរបស់សហគ្រាស ព្រមទាំងអាចផ្សព្វផ្សាយបានដល់អ្នកពាក់ព័ន្ធនានាដែលខ្លួនមានបំណងផ្តល់ដំណឹង

(ខ) ផ្តល់ព័ត៌មានដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីវាយតំលៃលើភាពគ្រប់គ្រាន់នៃការឆ្លើយតបរបស់សហគ្រាសនោះចំពោះការប៉ះពាល់សិទ្ធិមនុស្សដែលខ្លួនមានការពាក់ព័ន្ធ

(គ) ដូចគ្នាផងដែរ មិនត្រូវបង្កហានិភ័យដល់អ្នកពាក់ព័ន្ធដែលរងការប៉ះពាល់ បុគ្គលិក ឬដល់លក្ខខ័ណ្ឌតំរូវស្របច្បាប់នានា ខាងការសម្ងាត់របស់ពាណិជ្ជកម្មនោះទេ។

## ការដោះស្រាយ

២២. នៅពេលដែលសហគ្រាសពាណិជ្ជកម្មនានា កំណត់បានថា ពួកគេបានបង្ក ឬរួមចំណែកបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរ ពួកគេគួរតែផ្តល់ ឬធ្វើសហប្រតិបត្តិការ ស្វែងរកដំណោះស្រាយតាមរយៈដំណើរការស្របច្បាប់នានា។

## កត្តានានានៃបរិបទ

២៣. នៅក្នុងគ្រប់បរិបទទាំងអស់ សហគ្រាសពាណិជ្ជកម្មគួរតែះ

(ក) អនុលោមតាមច្បាប់ជាធរមានទាំងអស់ និងគោរពសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅគ្រប់ទីកន្លែងដែលពួកគេធ្វើប្រតិបត្តិការ

(ខ) ស្វះស្វែងរកមធ្យោបាយដើម្បីលើកកំពស់ដល់គោលការណ៍សិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅពេលប្រឈមមុខនឹងលក្ខខ័ណ្ឌតំរូវដែលមានវិវាទគ្នា

(គ) ចាត់ទុកហានិភ័យនៃការបង្ក ឬរួមចំណែកបង្កឲ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ថាជាបញ្ហាដែលត្រូវទទួលខុសត្រូវតាមច្បាប់នៅគ្រប់ទីកន្លែងដែលពួកគេធ្វើប្រតិបត្តិការ។

២៤. នៅពេលដែលមានការចាំបាច់ ដើម្បីចាត់អាទិភាពលើចំណាត់ការនានាក្នុងការដោះស្រាយការប៉ះពាល់ធ្ងន់ធ្ងរជាក់ស្តែង ឬជាសក្តានុពលលើសិទ្ធិមនុស្ស សហគ្រាសពាណិជ្ជកម្មនានាគួរតែស្វះស្វែងបង្ការ និងកាត់បន្ថយការប៉ះពាល់នានា ដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុត ឬប្រសិនបើពន្យាពេលការឆ្លើយតប អាចនឹងបណ្តាលឲ្យការប៉ះពាល់ទាំងនោះមិនអាចដោះស្រាយបាន។

## III. ការទទួលបានការដោះស្រាយ

### ក.គោលការណ៍ជាមូលដ្ឋាន

២៥. ជាផ្នែកមួយនៃភារកិច្ចរបស់ពួកគេ ក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សដែលទាក់ទងនឹងធុរកិច្ច រដ្ឋនានាត្រូវតែចាត់វិធានការសមស្រប តាមរយៈផ្លូវតុលាការ រដ្ឋបាល នីតិបញ្ញត្តិ ឬតាមមធ្យោបាយសមស្របផ្សេងៗទៀត ដើម្បីធានាថា នៅពេលដែលមានការរំលោភបែបនោះកើតឡើងនៅក្នុងដែនដី និង/ឬដែនសមត្ថកិច្ចរបស់ខ្លួន អ្នកដែលទទួលរងការប៉ះពាល់នឹងទទួលបានការដោះស្រាយ ប្រកបដោយប្រសិទ្ធិភាព។

### ខ.គោលការណ៍ប្រតិបត្តិការ

### យន្តការដោះស្រាយតាមប្រព័ន្ធតុលាការរបស់រដ្ឋ

២៦. រដ្ឋគួរតែចាត់វិធានការសមស្រប ដើម្បីធានាប្រសិទ្ធិភាពនៃយន្តការតុលាការក្នុងស្រុក នៅពេលដែលដោះស្រាយការរំលោភសិទ្ធិ

មនុស្សនានាដែលទាក់ទងនឹងធុរកិច្ច រួមទាំងការពិចារណាលើមធ្យោបាយនានា ដើម្បីកាត់បន្ថយការប្រើប្រាស់នីតិវិធីតាមផ្លូវច្បាប់ ការអនុវត្តន៍នានា និងរបាំងដែលពាក់ព័ន្ធផ្សេងៗទៀតដែលអាចនាំឲ្យរាំងស្ទះដល់ការទទួលបានការដោះស្រាយ។

## យន្តការដោះស្រាយរបស់រដ្ឋក្រៅប្រព័ន្ធតុលាការ

២៧. រដ្ឋនានាគួរតែ ផ្តល់យន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការដ៏មានប្រសិទ្ធិភាព និងសមស្រប ទន្ទឹមគ្នានឹងយន្តការតាមប្រព័ន្ធតុលាការ ដែលជាផ្នែកមួយនៃប្រព័ន្ធដោះស្រាយដ៏ទូលំទូលាយរបស់រដ្ឋ សម្រាប់ធ្វើការដោះស្រាយការរំលោភសិទ្ធិមនុស្សទាក់ទងនឹងធុរកិច្ច។

## យន្តការដោះស្រាយមិនមែនរបស់រដ្ឋ

២៨. រដ្ឋនានាគួរតែពិចារណារកមធ្យោបាយសម្រាប់សម្របសម្រួលដល់ការទទួលបាននូវយន្តការដោះស្រាយមិនមែនរបស់រដ្ឋដ៏មានប្រសិទ្ធិភាព ដើម្បីដោះស្រាយព្យសនកម្មនានាខាងសិទ្ធិមនុស្សដែលទាក់ទងនឹងធុរកិច្ច។

២៩. ដើម្បីបង្កភាពងាយស្រួលសម្រាប់ការដោះស្រាយឲ្យបានឆាប់រហ័ស និងដោយផ្ទាល់ សហគ្រាសពាណិជ្ជកម្មនានាគួរតែបង្កើតឬចូលរួមនៅក្នុងយន្តការដោះស្រាយកំរិតប្រតិបត្តិការដ៏មានប្រសិទ្ធិភាព សម្រាប់បុគ្គល និងសហគមន៍នានាដែលអាចទទួលរងការប៉ះពាល់ធ្ងន់ធ្ងរ។

៣០. ឧស្សាហកម្ម អ្នកពាក់ព័ន្ធពហុភាគី និងកិច្ចផ្តួចផ្តើមកិច្ចសហប្រតិបត្តិការផ្សេងៗទៀត ដែលធ្វើប្រតិបត្តិការផ្អែកលើការគោរពបទដ្ឋានសិទ្ធិមនុស្ស គួរតែធានាឲ្យមាននូវយន្តការដោះស្រាយប្រកបដោយប្រសិទ្ធិភាព។

## លក្ខណៈវិនិច្ឆ័យដ៏មានប្រសិទ្ធិភាពសម្រាប់យន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ

៣១. ដើម្បីធានាដល់ប្រសិទ្ធិភាពនៃយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការទាំងរបស់រដ្ឋ និងមិនមែនរបស់រដ្ឋ យន្តការទាំងនោះគួរតែះ

(ក) ស្របច្បាប់ះ ទទួលបានទំនុកចិត្តពីក្រុមអ្នកពាក់ព័ន្ធនានាដែលជា កម្មវត្ថុនៃយន្តការទាំងនោះ ព្រមទាំងមានគណនេយ្យភាពចំពោះការប្រព្រឹត្តដោយយុត្តិធម៌លើដំណើរការដោះស្រាយនានា

(ខ) អាចប្រើប្រាស់បានះ ត្រូវបានយល់ដឹងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងអស់ ដែលជាកម្មវត្ថុនៃយន្តការទាំងនោះ ព្រមទាំងផ្តល់ជំនួយឧបត្ថម្ភគ្រប់គ្រាន់ដល់អ្នក ដែលអាចប្រឈមមុខនឹងរបាំងដោយឡែកណាមួយ ដែលរារាំងមិនឲ្យពួកគេប្រើប្រាស់យន្តការទាំងនោះបាន

(គ) អាចព្យាករណ៍បានះ ផ្តល់នីតិវិធីច្បាស់លាស់ និងងាយស្រួលយល់ អមជាមួយនឹងតារាងពេលវេលាសម្រាប់ដំណាក់កាលដោះស្រាយនិមួយៗ ហើយពន្យល់យ៉ាងច្បាស់លាស់អំពីប្រភេទនៃដំណើរការ និងលទ្ធផលដែលមានព្រមទាំងវិធីសាស្ត្រតាមឃ្លាំមើលការអនុត្តន៍

(ឃ) សមធម៌៖ ស្វះស្វែងធានាថា ភាគីរងគ្រោះនានាទទួលបាន ព័ត៌មាន ការប្រឹក្សា និងជំនាញការសមស្របដែលចាំបាច់ សម្រាប់ចូលរួមក្នុងដំណើរការដោះស្រាយដែលមានលក្ខណៈ យុត្តិធម៌ មានព័ត៌មានគ្រប់គ្រាន់ និងដោយការគោរព

(ង) តម្លាភាព៖ ភាគីនានានៃយន្តការនេះត្រូវទទួលបានការជូន ដំណឹង ជាប់ជានិច្ចអំពីការវិវត្តទៅមុខនៃនីតិវិធី ព្រមទាំងផ្តល់ ព័ត៌មានគ្រប់គ្រាន់អំពីការប្រព្រឹត្តទៅនៃយន្តការនេះ ដើម្បី កសាងទំនុកចិត្តលើប្រសិទ្ធិភាពនៃយន្តការ និងការពារផល ប្រយោជន៍សាធារណៈណាមួយ ដែលប្រឈមមុខនឹង ហានិភ័យ

(ច) សិទ្ធិជានិរន្តរ៍៖ ធានាថា លទ្ធផលនិងការដោះស្រាយអនុលោម តាមសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ

(ឆ) ប្រភពនៃការសិក្សាជាបន្ត៖ ស្រង់ចេញពីវិធានការពាក់ព័ន្ធ នានា កំណត់យកមេរៀន ដើម្បីធ្វើឲ្យប្រសើរឡើងដល់យន្ត ការនេះ ព្រមទាំង បង្ការវិវាទ និងព្យសនកម្មនាពេលអនាគត

**យន្តការកំរិតប្រតិបត្តិការក៏គួរតែមានលក្ខណៈដូចខាងក្រោមផងដែរ៖**

(ជ) ផ្អែកលើការចូលរួម និងការសន្ទនា៖ ពិគ្រោះយោបល់ជាមួយ ក្រុមអ្នកពាក់ព័ន្ធនានាដែលជាកម្មវត្ថុនៃយន្តការទាំងនេះ អំពី ការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការទាំងនេះ ព្រមទាំង ផ្តោតការយកចិត្តទុកដាក់លើការសន្ទនា ធ្វើជាវិធីសាស្ត្រក្នុង ការដោះស្រាយវិវាទ។